# មេរៀនទី ១៧: ព្រះយេស៊ូវត្រូវបានឆ្កាង

## លូកា ១៩:២៨-៤០, ២៣:១-៤៩

**គោលបំណង៖** ព្រះយេស៊ូវសុគតដើម្បីលោះបាបយើង។

**ខគម្ពីរចងចាំ៖ រ៉ូម ៦:២៣** *"ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ដោយសារតែជីវិតរបស់យើងគឺមានភាពរវល់ខ្លាំង ដែលវាងាយស្រួលធ្វើឲ្យយើងភ្លេចថា ព្រះគឺជាអ្វីគ្រប់យ៉ាងនៅក្នុងជីវិតនេះ។ ប៉ុន្តែអ្វីៗគ្រប់យ៉ាងដែលបានបង្កើតឡើងមកនោះ ប្រាប់យើងថាទ្រង់ជាព្រះអទិករ។ សូមអរព្រះគុណព្រះ ដែលយើងមានក្តីស្រឡាញ់ និងមានទំនាក់ទំនងជាមួយនឹងព្រះយេស៊ូវ! ដូចជានៅក្នុងព្រះគម្ពីរបានបង្រៀនយើងនៅថ្ងៃនេះ សូម្បីតែថ្មក៏អាចសរសើរដំកើងព្រះយេស៊ូវបានដែរ។ ពីសថ្ម តើពាក្យនេះប្រាប់យើងអ្វីខ្លះពីព្រះ? វាគួរតែប្រាប់អ្នកពីការអស្ចារ្យរបស់ព្រះអាទិករដែលគ្មានការចាប់ផ្តើមហើយក៏មានទីបញ្ចប់។ សូមសរសេរដំកើងព្រះមេស្ស៊ីរបស់អ្នកគ្រប់ពេលទាំងអស់។

**ចំរៀង៖** ១.ហូសាណា ២.មានទន្លេជីវិត ៣. ពេលខ្យល់ព្យុះបក់ខ្លាំង

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «ក្រហម បៃតង លឿង ទឹកក្រូច»**

**ជំពីសទី១**

**សម្ភារៈដែលត្រូវការ៖**ប្រើហ្វឺតពណ៌ដើម្បីសរសេរឈ្មោះពណ៌លើក្រដាសសដោយប្រើពណ៌ខុសៗគ្នា (ឧទាហរណ៍៖សរសេរពាក្យថា "ពណ៌បៃតង" ដោយប្រើហ្វឺត ពណ៌ក្រហម )

១. បែងចែកកុមារជាក្រុម ដោយក្នុងមួយក្រុមត្រូវមានកុមារ៥នាក់។

២. ក្រុមនីមួយៗចាត់កុមារម្នាក់មកលេងល្បែងនេះ។

៣. បន្ទាបពីកុមារតំណាងឲ្យក្រុមនីមួយៗចេញមកហើយ គ្រូត្រូវបង្ហាញក្រដាសដែល មានឈ្មោះពណ៌។ កុមារទី១ដែលបានអានឈ្មោះពណ៌ត្រូវនឹងឈ្នះល្បែងនេះ។ ឧទាហរណ៍៖ បើនៅក្នុងក្រដាសមានពាក្យ ថា"ពណ៌បៃតង" ប៉ុន្តែពណ៌ដែលសរសេរគឺក្រហម ចំលើយដែលត្រឹមត្រូវគឺ "ពណ៌បៃតង"

| |
|---|
| បៃតង |
| ក្រហម |
| លឿង |
| ទឹកក្រូច |

៤. លេងល្បែងនេះរហូតដល់អស់ពណ៌លេង។

៥. សូមប្រាប់កុមារថាយើងជ្រើសរើសពណ៌ខុស ពីព្រោះយើងមិនគ្រប់លក្ខណ៍ទេ ប៉ុន្តែអ្នកដែលគ្រប់លក្ខណ៍នោះគឺព្រះយេស៊ូវ។

**ជំពីសទី២៖** (ភ្លើងស្តុប ពណ៌លឿង ក្រហម បៃតង)

១. ឲ្យកុមារឈរ១ជួរ
២. បើគ្រូស្រែកថាពណ៌លឿងកុមារដើរយឺតៗបើគ្រូស្រែកថាពណ៌បៃតងកុមារត្រូវរត់ទៅមុខឲ្យលឿន ពណ៌ក្រហមកុមារត្រូវឈប់នៅស្ងៀម
៣. បើកុមារណាមិនឈប់គេត្រូវចាញ់ ឲ្យកុមារនៅមួយកន្លែង យើងបន្តលេងទៀតរហូតនៅសល់កុមារ៥ ទៅ ១០ នាក់ អាស្រ័យទៅលើការកំណត់របស់គ្រូ។

## ៤. ការណែនាំមេរៀន

តើមនុស្សប្រភេទណាដែលត្រូវប៉ូលីសចាប់ដាក់គុក? គឺជាអ្នកដែលមានទោសពីបទលួច សំឡាប់ និងអ្នកប្រព្រឹត្តហិង្សាគួរតែជាប់គុក។ តើអ្នកមានអារម្មណ៍យ៉ាងណាបើអ្នកមិនបានធ្វើខុស តែត្រូវប៉ូលីសចាប់អ្នកដាក់គុក? តើអ្នកនឹងរកវិធីយ៉ាងណាដើម្បីចេញពីគុកមែនដែរឬទេ? ព្រះយេស៊ូវមិនបានធ្វើអ្វីខុសសោះឡើយនៅក្នុងជីវិតរបស់ទ្រង់។ ទ្រង់ជាព្រះរាជបុត្រានៃព្រះ ប៉ុន្តែព្រះអង្គបានយាងមកដើម្បីនឹងជួយសង្គ្រោះពួកយើង។ ប៉ុន្តែមនុស្សជាច្រើនបានចាប់ទ្រង់ ហើយចង់សម្លាប់ទ្រង់ថែមទៀតផង។សូមយើងរៀនអំពីរឿងរបស់ព្រះយេស៊ូនៅថ្ងៃនេះ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅក្នុងព្រះគម្ពីរបានប្រាប់យើងអំពីគ្រាមួយ ជាពេលដែលព្រះយេស៊ូវជិះសត្វលាទៅកាន់ទីក្រុងយេសាឡិមហ្វូងមនុស្សបានឈរនៅលើផ្លូវ ហើយគ្រវីមែកចាក។ ពួកគេរំភើបចិត្ត ដោយសារពួកគេខ្លះគិតថា ព្រះយេស៊ូវធ្វើដំណើរចូលមកទីក្រុងដើម្បីធ្វើជាស្តេចរបស់ពួកគេ។ ពួកគេស្រែកឡើងថា៖ **លូកា ១៩:៣៨** «ស្ដេចដែលយាងមកដោយនូវព្រះនាមព្រះអម្ចាស់ ទ្រង់ប្រកបដោយព្រះពរ សូមឲ្យបានសេចក្ដី ក្សេមក្សាន្តនៅស្ថានសួគ៌ និងសិរីល្អនៅស្ថានដ៏ខ្ពស់បំផុត» ពួកគេបានចាត់ទុកទ្រង់ដូចជាស្ដេចដ៏អស្ចារ្យ។

ប៉ុន្មានថ្ងៃក្រោយ បន្ទាប់ពីចូលទៅក្នុងទីក្រុងព្រះយេស៊ូវត្រូវបានចាប់ខ្លួន នៅពេលដែលទ្រង់មិនបានធ្វើអ្វីខុសសោះ។ អ្នកដឹកនាំមិនបានដឹងថាទ្រង់ជាព្រះរាជបុត្រារបស់ព្រះនោះទេ។ ពួកគេមិនចូលចិត្តស្ដាប់មនុស្សសរសើរព្រះយេស៊ូវ ហើយគោរពទ្រង់ដូចជាស្ដេចនោះឡើយ។ ដូច្នេះទោះបីជាព្រះយេស៊ូវមិនបានធ្វើអ្វីខុសក៏ដោយក៏ពួកគេបានសម្លាប់ទ្រង់ដោយឆ្កាងព្រះយេស៊ូវនៅលើឈើឆ្កាងដែរ។

ប៉ុន្តែព្រះមានផែនការផ្សេងពីនេះ។ ព្រះបានអនុញ្ញាតឲ្យព្រះយេស៊ូវសុគតដើម្បីលោះនូវអំពើបាបរបស់យើង ជាកិច្ចការទាំងឡាយណាដែលយើងធ្វើហើយមិនគាប់ព្រះហឫទ័យព្រះ។ ពេលយើងធ្វើអំពើអាក្រក់ យើងសមនឹងទទួលនូវការដាក់ទោស។ អំពើបាបបំបែកយើងចេញពីព្រះ។ ព្រះគម្ពីរ **រ៉ូម ៦:២៣** ចែងថា «ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្ដីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រីស្ទយេស៊ូវជាព្រះអម្ចាស់នៃយើងរាល់គ្នា»។ ដោយសារព្រះស្រឡាញ់យើង ទើបបានជាទ្រង់បានបញ្ជូនព្រះយេស៊ូវឲ្យមកសុគតជំនួសយើង! ទ្រង់ទទួលទោសជំនួសយើង! ព្រះយេស៊ូវមិនគ្រាន់តែសុគតសម្រាប់អ្នកមានឬមនុស្សល្បីនោះទេ។ ព្រះយេស៊ូវបានសុគតសម្រាប់មនុស្សគ្រប់រូបរួមទាំងអ្នក និងខ្ញុំផង! ដោយសារព្រះយេស៊ូវបានសុគតជំនួសយើងនៅលើឈើឆ្កាង ឥឡូវនេះអ្នកអាចនៅជាមួយនឹងព្រះបាន។ យើងអរព្រះគុណព្រះយេស៊ូវដែលបានសុគតជំនួសយើង។

## ៦. សំនួរពិភាក្សា

១. តើមនុស្សគិតថាព្រះយេស៊ូវនឹងធ្វើអ្វីពេលទ្រង់ចូលក្រុងយេរូសាឡិមដោយជិះសត្វលា?

*ពួកគេគិតថាទ្រង់នឹងក្លាយជាស្តេច*

២. តើមានអ្វីកើតឡើងចំពោះព្រះយេស៊ូវ បន្ទាប់ពីពីរបីថ្ងៃក្រោយមក?

*ទ្រង់ត្រូវបានចាប់ខ្លួន ហើយឆ្កាងនៅលើឈើឆ្កាង*

៣. តើអំពើបាបធ្វើអ្វីចំពោះទំនាក់ទំនងរបស់យើងជាមួយព្រះ? *វាបំបែកយើងពីព្រះ*

៤. ដោយសារព្រះយេស៊ូវបានសុគតជំនួសយើង តើមានអ្វីកើតឡើងចំពោះអំពើបាបរបស់យើង?

*ព្រះយេស៊ូវបានទទួលយកអំពើបាបរបស់យើង ហើយសុគតជំនួសអំពើបាបរបស់យើង។*

៥. តើអ្នកអាចអរព្រះគុណព្រះយេស៊ូវដែលបានសុគតជំនួសអ្នកយ៉ាងដូចម្តេច ដើម្បីឲ្យអ្នកបាននៅជាមួយនឹងព្រះ? *ឱ្យកុមារឆ្លើយ  អធិស្ឋាន អានព្រះគម្ពីរ សប្បុរស ស្រឡាញ់អ្នកដទៃទៀតឲ្យកុមារនិយាយថា អរគុណព្រះយេស៊ូវដែលបានសុគតជំនួសអំពើបាបយើង*

## ៧. ល្បែងកំសាន្ត «ព្រះយេស៊ូវលោះបានយើង»

**សម្ភារៈដែលត្រូវការ៖** ក្រដាស៤០-៥០ សន្លឹក



១.សុំឱ្យកុមារឆ្នូលក្រដាសឱ្យបានច្រើនសន្លឹកតាមដែលអាចធ្វើទៅបាន ហើយដាក់វានៅកណ្តាលថ្នាក់រៀន

២. ចែកកុមារជា ២ ក្រុម។

៣. ក្រដាសដែលបានឆ្នូលទាំងនោះតំណាងឱ្យ អំពើបាបនៅក្នុងជីវិតរបស់យើង។

៤. ក្រុមទី ១ នឹងព្យាយាមគប់អំពើបាបរបស់ពួកគេសំដៅទៅកាន់ក្រុមទី២។ នេះតំណាងឱ្យពួកគ្រីស្ទានដែលព្យាយាមរស់នៅក្នុងជីវិតរស់នៅដូចជាព្រះ។

៥. ក្រុមទី២ នឹងគប់ក្រដាសត្រឡប់ទៅក្រុមទី ១។ នេះតំណាងឱ្យលោកីយ៍ដែលធ្វើឱ្យយើងមានការលំបាកក្នុងការរួចផុតពីអំពើបាប។

៦. ក្រុមទី១ ត្រូវតែប្រឹងប្រែងដើម្បីបោះចោលក្រដាសឆ្នូលឲ្យបានច្រើនចេញឆ្ងាយពីពួកគេដើម្បីឈ្នះការប្រកួត (គ្រូត្រូវកំណត់នាទីក្នុងការលេងល្បែងនេះ)

៧. ពន្យល់ដល់កុមារថា វាមិនអាចទៅរួចទេសម្រាប់យើងដើម្បីកម្ចាត់អំពើបាបរបស់យើងទាំងអស់ចេញបាន។ ដូច្នេះហើយបានជាព្រះយេស៊ូវបានសុគតជំនួសយើងនៅលើឈើឆ្កាង។ ព្រះយេស៊ូវបានទទួលយកអំពើបាបរបស់យើងទាំងអស់ ។ ឥឡូវនេះ យើងត្រូវតែជ្រើសរើសរស់នៅជាមួយនឹងជីវិត ដែលធ្វើឲ្យព្រះសព្វព្រះទ័យ។

## ៨. ខគម្ពីរចងចាំ រ៉ូម ៦:២៣

## ៩. ហត្ថកម្ម ផាត់ពណ៌ហើយឲ្យពួកគេចាំថាព្រះយេស៊ូវបានសុគតជំនួសបាបយើង

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

បៃតង

ក្រហម

លឿង

ទឹកក្រូច

# ព្រះយេស៊ូវនៅលើឈើឆ្កាង

